# ច្បាប់ស្តីពីទូរគមនាគមន៍កម្ពុជា

## បទវិភាគផ្នែកច្បាប់

---

របាយការណ៍សង្ខេប អង្គការ លីកាដូ
ខែមីនា ២០១៦


សម្ព័ន្ធខ្មែរជំរឿននិងការពារសិទ្ធិមនុស្ស លីកាដូ

**LICADHO**

CAMBODIAN LEAGUE FOR THE PROMOTION AND
DEFENSE OF HUMAN RIGHTS

## សេចក្ដីផ្ដើម

ច្បាប់ថ្មីមួយស្ដីពីប្រព័ន្ធទូរគមនាគមន៍ ("ច្បាប់ស្ដីពីទូរគមនាគមន៍") បង្កើតឲ្យមាននូវការប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សេរីភាពនៃការបញ្ចេញមតិនៅក្នុងប្រទេសកម្ពុជា ដោយច្បាប់នេះមិនត្រឹមតែផ្ដោតសំខាន់ទៅលើការបញ្ចេញមតិជាសាធារណៈលើប្រព័ន្ធអ៊ិនធើណេតប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងទៅលើទំនាក់ទំនងជាឯកជនតាមរយៈការប្រើប្រាស់ឧបករណ៍ទូរគមនាគមន៍នានា។

បទប្បញ្ញត្តិយ៉ាងតឹងរឹងរបស់ច្បាប់នេះ ផ្ដល់សិទ្ធិអំណាចដល់រាជរដ្ឋាភិបាលក្នុងការចូលដោយសម្ងាត់ទៅក្នុងជីវិតឯកជនរបស់បុគ្គល បំផ្លាញភស្តុតាងមុនពេលជំនុំជម្រះក្ដីព្រហ្មទណ្ឌ និងគ្រប់គ្រងលើឧស្សាហកម្មទូរគមនាគមន៍ទាំងមូលប្រសិនបើមានការសម្រេចថាចង់ធ្វើ។

វិធានការលើសលុបរបស់ច្បាប់នេះ ជាពិសេសចំពោះមាត្រាជាច្រើនដែលបង្កើតបទល្មើសព្រហ្មទណ្ឌថ្មី បង្ហាញអំពីចេតនាពិតនៃច្បាប់នេះ៖ ដើម្បីបំភិតបំភ័យបុគ្គលម្នាក់ៗ ដាក់ទណ្ឌកម្មដល់ការអនុវត្តសិទ្ធិនិងសេរីភាពជាមូលដ្ឋាន និងកាត់បន្ថយបុគ្គល ឬក្រុមជំទាស់។ នៅក្នុងរយៈពេលមួយឆ្នាំមុនរហូតដល់ការបោះឆ្នោតឃុំ-សង្កាត់ឆ្នាំក្រោយ និងពីរឆ្នាំក្រោយនៅពេលមានការបោះឆ្នោតថ្នាក់ជាតិនេះហាក់ដូចជារាជរដ្ឋាភិបាលកម្ពុជាបានរៀបចំជាមួយនឹងឧបករណ៍ថ្មីមួយដែលនឹងជាការរារាំងដល់សង្គមស៊ីវិល។

ការវិភាគខាងក្រោមនឹងលម្អិតអំពីការប៉ះពាល់យ៉ាងយ៉ាងធ្ងន់ធ្ងរនានាដែលបង្កឡើងដោយច្បាប់នេះ ដោយស្ថិតនៅក្រោមប្រធានបទអំណាចត្រួតពិនិត្យចាប់ពិរុទ្ធ ការរឹតត្បិតសេរីភាពជាមូលដ្ឋានគ្រោះថ្នាក់ទៅដល់សិទ្ធិនៃការជំនុំជម្រះក្ដីប្រកបដោយយុត្តិធម៌ ការពិនិត្យនិងពង្រឹងការអនុវត្តច្បាប់ និងការគ្រប់គ្រងលើសលុបរបស់អាជ្ញាធររដ្ឋ។[១]

## អំណាចឃ្លាំមើល

គោលបំណងដែលត្រូវបានចែងដោយច្បាប់នេះ គឺបទប្បញ្ញត្តិនៃឧស្សាហកម្មទូរគមនាគមន៍ ប៉ុន្តែច្បាប់នេះមានមាត្រាជាច្រើន ដែលផ្ដល់អំណាចដល់អាជ្ញាធររដ្ឋក្នុងការតាមដានដោយសម្ងាត់ទៅលើទូរគមនាគមន៍របស់បុគ្គលម្នាក់ៗដោយមិនចាំបាច់មានការទទួលខុសត្រូវណាមួយ និងសិទ្ធិអំណាចក្នុងការដាក់ទោសបុគ្គលទាំងនោះ ប្រសិនបើទំនាក់ទំនងរបស់អ្នកទាំងនោះត្រូវបានចាត់ទុកជាបទល្មើសព្រហ្មទណ្ឌ។ ច្បាប់នេះ ត្រូវបានចែងដោយមិនបានផ្អែកលើសិទ្ធិសេរីភាពនៃការ

[១] ការវិភាគនេះគឺផ្អែកលើការបកប្រែជាភាសាអង់គ្លេសក្រៅផ្លូវការនៃច្បាប់ស្ដីពីទូរគមនាគមន៍ និងច្បាប់ស្ដីពី ទូរគមនាគមន៍ ចេញផ្សាយនៅលើគេហទំព័ររបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍។

បញ្ចេញមតិ ឬការការពារនានា ដូចដែលបានធានាដោយរដ្ឋធម្មនុញ្ញ និងច្បាប់អន្តរជាតិ[២] ហើយក៏មិនបានផ្អែកលើសិទ្ធិឯកជនភាពក្នុងការឆ្លើយឆ្លងតាមមធ្យោបាយទូរគមនាគមន៍ ដែលត្រូវបានការពារដោយស្ថិតនៅក្រោមរដ្ឋធម្មនុញ្ញនោះទេ។[៣]

- មាត្រា ៩៧ នៃច្បាប់នេះ អនុញ្ញាតឲ្យមានការតាមដានដោយសម្ងាត់តាមប្រព័ន្ធទូរគមនាគមន៍ណាមួយនិងទាំងអស់ ដោយការតាមដាននេះត្រូវបានធ្វើឡើងដោយមានការយល់ព្រមពី "អំណាចស្របច្បាប់" មួយ។[៤] មិនមានចែងអំពីនិយមន័យនូវអ្វីដែលបង្កើតបានជា "អំណាចស្របច្បាប់" នោះទេ ឬមិនមានចែងថាតើអាជ្ញាធរអាចទទួលបានអំណាចក្នុងការយល់ព្រមឲ្យធ្វើការតាមដានបែបនេះដោយរបៀបណា។ នេះហាក់ដូចជាបង្កើតនូវអំណាច ដើម្បីលួចតាមដានជាសម្ងាត់ដោយគ្មានការទទួលខុសត្រូវ ឬការគាំពារសុវត្ថិភាពសាធារណៈណាមួយ ដើម្បីការពារសិទ្ធិរបស់បុគ្គលក្នុងការទទួលបានឯកជនភាព។ នេះមានន័យថាបុគ្គលណាម្នាក់ដែលធ្វើការសន្ទនាតាមទូរស័ព្ទ ផ្ញើសារ អ៊ីមែល ឬធ្វើទំនាក់ទំនងតាមប្រព័ន្ធផ្សព្វផ្សាយសង្គម អាចនឹងស្ថិតនៅក្រោមការស៊ើបអង្កេតដោយសម្ងាត់ នៅពេលណាមួយក៏បាន ដោយមិនចាំបាច់មានការដឹងលឺពីបុគ្គលទាំងនោះឡើយ។ ការសន្ទនាឯកជនណាមួយតាមរយៈទូរគមនាគមន៍នឹងលែងមានភាពឯកជនពិតប្រាកដតទៅទៀត។
- មាត្រា ៦ តម្រូវឲ្យ "គ្រប់ប្រតិបត្តិករទូរគមនាគមន៍ និងបុគ្គលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ត្រូវផ្តល់ទិន្នន័យសេវាទូរគមនាគមន៍ និងព័ត៌មានវិទ្យាមកក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍។"[៥] ចំពោះការអនុវត្ត ច្បាប់នេះផ្តល់នូវសិទ្ធិអំណាចដល់ក្រសួងដើម្បីទាមទារឲ្យគ្រប់ក្រុមហ៊ុនផ្តល់សេវាទូរគមនាគមន៍ទាំងអស់ត្រូវផ្តល់នូវទិន្នន័យរបស់អ្នកប្រើប្រាស់សេវារបស់ក្រុមហ៊ុន ហើយក៏ថែមទាំងអាចឲ្យអនុវត្តជាកាតព្វកិច្ចសម្រាប់ឲ្យក្រុមហ៊ុនប្រគល់ទិន្នន័យដោយមិនចាំបាច់មានដីកាតុលាការ ឬការការពារសិទ្ធិទទួលបានឯកជនភាពនោះទេ។ នេះគឺជាការរំលោភយ៉ាងច្បាស់លាស់លើកាតព្វកិច្ចរបស់កម្ពុជាក្រោមច្បាប់រដ្ឋធម្មនុញ្ញ និងច្បាប់អន្តរជាតិ។

---

[២] មាត្រា ៤១ នៃរដ្ឋធម្មនុញ្ញកម្ពុជា; មាត្រា ១៩ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ - ខណៈដែលមាត្រា ១៩ (៣) (ក) និង (ខ) មានដែនកំណត់អនុញ្ញាតចំនួនបួន ទៅលើសិទ្ធិសេរីភាពនៃការបញ្ចេញមតិ (មកទល់ពេលនេះដូចដែលវាត្រូវបានផ្តល់ឲ្យដោយច្បាប់ ជាចាំបាច់និងសមាមាត្រ) ដែលរួមមាន សន្តិសុខជាតិ និងសណ្តាប់ធ្នាប់សាធារណៈ នៅក្នុងបរិបទកម្ពុជា ការបកស្រាយមិនត្រឹមត្រូវដោយចេតនា និងដោយបំពាន ធ្វើឡើងដោយអាជ្ញាធរ ទៅលើការបញ្ចេញមតិ មានន័យថាការបញ្ចេញមតិស្របច្បាប់ជាញឹកញាប់ត្រូវបានចាត់ទុកដោយមិនត្រឹមត្រូវថាជា ការគំរាមកំហែងដល់សន្តិសុខជាតិ។

[៣] មាត្រា ៤០ នៃរដ្ឋធម្មនុញ្ញកម្ពុជា

[៤] មាត្រា ៩៧ នៃច្បាប់ស្តីពីទូរគមនាគមន៍

[៥] មាត្រា ៦ នៃច្បាប់ស្តីពីទូរគមនាគមន៍

រដ្ឋធម្មនុញ្ញបានធានានូវសិទ្ធិដើម្បីរក្សាការសម្ងាត់នៃការឆ្លើយឆ្លង[៦] ដូចនេះអំណាចដ៏ទូលំទូលាយដែលគ្មានការត្រួតពិនិត្យ ដើម្បីទាញយកទិន្នន័យទាក់ទងនឹងសកម្មភាពទូរគមនាគមន៍របស់បុគ្គល គឺជាការរំលោភសិទ្ធិនេះ។ លើសពីនេះទៀតរដ្ឋធម្មនុញ្ញបានទទួលស្គាល់កាតព្វកិច្ចរបស់កម្ពុជាក្រោមកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដើម្បីការពារបុគ្គលទៅនឹងការជ្រៀតជ្រែកដោយមិនត្រឹមត្រូវ និងខុសច្បាប់ទៅក្នុងឯកជនភាពនិងការឆ្លើយឆ្លងរបស់បុគ្គល ហើយតម្រូវឲ្យមានច្បាប់ដើម្បីការពារបុគ្គលទៅនឹងការរំលោភបំពានបែបនេះ។[៧]

## ការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌលើការបញ្ចេញមតិ និងការរឹតត្បិតសិទ្ធិសេរីភាព

ទន្ទឹមនឹងអំណាចឃ្លាំមើលទូលំទូលាយ ច្បាប់នេះក៏បានបង្កើតនូវបទល្មើសព្រហ្មទណ្ឌថ្មីជាច្រើនដែលទាក់ទងទៅនឹងការប្រើប្រាស់ឧបករណ៍ទូរគមនាគមន៍។ បទល្មើសទាំងនេះអាចនឹងមានការផ្តន្ទាទោសជាប់ពន្ធនាគារ និងការផាកពិន័យធ្ងន់ធ្ងរ។ ការរួមបញ្ចូលគ្នានៃអំណាចឃ្លាំមើល និងបទល្មើសថ្មីៗជាច្រើននេះ មានន័យថាគ្រប់ការបញ្ចេញមតិជាសាធារណៈឬជាឯកជន តាមរយៈឧបករណ៍ទូរគមនាគមន៍ អាចនឹងត្រូវបានត្រួតពិនិត្យ និងបកប្រែជាបទល្មើសមួយ។ នេះជាសក្តានុពលយ៉ាងខ្លាំងដែលអាចនឹងនាំមកនូវឥទ្ធិពលគួរឲ្យព្រួយបារម្ភមួយទៅលើការបញ្ចេញមតិរបស់បុគ្គល និងរបស់សមាគមតាមរយៈប្រព័ន្ធទូរគមនាគមន៍។ លើសពីនេះ បទប្បញ្ញត្តិទាំងនេះអាចនឹងត្រូវបានគេប្រើប្រាស់ដើម្បីតាមដានដោយសម្ងាត់លើបុគ្គលសំខាន់ៗ ហើយនឹងអាចបកស្រាយអត្ថបទនៃទំនាក់ទំនងរបស់បុគ្គលទាំងនោះថាជាបទល្មើសព្រហ្មទណ្ឌ។

ខាងក្រោមនេះ គឺជាការវិភាគមួយចំនួននៃបទប្បញ្ញត្តិដែលបង្កើតនូវការប៉ះពាល់យ៉ាងធ្ងន់ធ្ងរបំផុតចំពោះសិទ្ធិ និងសេរីភាពរបស់បុគ្គលៈ

- មាត្រា ៨០ ចែងថា "ការបង្កើត ការដំឡើង ការប្រើប្រាស់គ្រឿងសម្ភារៈបរិក្ខារវិស័យទូរគមនាគមន៍ កាលបើអំពើនេះអាចនាំឲ្យអសន្តិសុខជាតិ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៧ (ប្រាំពីរ) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ។"[៨] មិនមានសកម្មភាពទូរគមនាគមន៍ណាមួយហាក់បីដូចជាត្រូវបានដកចេញនោះទេ។ នេះមានន័យថាទម្រង់នៃការបញ្ចេញមតិ ជាសាធារណៈ ឬជាឯកជនណាមួយដែលធ្វើឡើងដោយមធ្យោបាយទំនាក់ទំនងអេឡិចត្រូនិណាមួយ អាចនឹងត្រូវជាប់

[៦] មាត្រា ៤០ នៃរដ្ឋធម្មនុញ្ញកម្ពុជា

[៧] មាត្រា ៣១ នៃរដ្ឋធម្មនុញ្ញកម្ពុជា; មាត្រា ១៧ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ

[៨] មាត្រា ៨០ នៃច្បាប់ស្តីពីទូរគមនាគមន៍

ទោសព្រហ្មទណ្ឌ ប្រសិនបើសកម្មភាពនោះត្រូវបានចាត់ទុកថាធ្វើឲ្យមាន "អសន្តិសុខជាតិ" ។ នេះអាចជាការដាក់ទោសធ្ងន់ធ្ងរលើការបញ្ចេញមតិស្របច្បាប់តាមរយៈកម្មវិធីវិទ្យុ ទូរទស្សន៍ បណ្តាញអ៊ិនធើណេត និងសូម្បីតែតាមរយៈសារជាអក្សរលក្ខណៈឯកជន និងការសន្ទនាតាមទូរស័ព្ទរវាងបុគ្គលនិងបុគ្គល ប្រសិនបើអាជ្ញាធរកំណត់ថាសកម្មភាពនោះជាការគម្រាមកំហែងមួយ។ បទល្មើសនេះហាក់ដូចជាដាក់ឲ្យមានការទទួលខុសត្រូវយ៉ាងតឹងរ៉ឹង ដោយមិនចាំបាច់មានបំណងដើម្បីបង្កឲ្យមានអសន្តិសុខជាតិនោះទេ ក៏បុគ្គលម្នាក់អាចប្រឈមមុខនឹងការជាប់ពន្ធនាគារ ១៥ ឆ្នាំ និងការពិន័យហួសហេតុជាប្រាក់ពី ១៥០លាន ទៅ ៣០០ រៀលលានរៀលដែរ។[៩] ដោយសារភាពមិនច្បាស់លាស់នៃច្បាប់នេះ មានន័យថាភាពស្របច្បាប់នៃសកម្មភាពមួយ គឺមិនមានភាពច្បាស់លាស់សំរាប់បុគ្គលណាមួយនៅពេលបុគ្គលនោះប្រព្រឹត្តសកម្មភាពនោះទេ ប៉ុន្តែសកម្មភាពនេះបែរជាត្រូវបានគេបកស្រាយយ៉ាងច្បាស់នៅពេលក្រោយទៅវិញដោយផ្អែកលើលទ្ធផលនៃសកម្មភាពនោះ។ នេះធ្វើឲ្យបទបញ្ញត្តិ និងនិយមន័យ "អសន្តិសុខជាតិ" នេះមានលក្ខណៈទូលំទូលាយ ដែលអាចត្រូវបានគេទាញយកមកប្រើប្រាស់បានយ៉ាងងាយស្រួលដោយប្រព័ន្ធតុលាការគាំទ្រគណបក្សនយោបាយមួយនៅក្នុងប្រទេសកម្ពុជា។

- ក្រៅពីបទល្មើសថ្មីដែលបានបង្កើត មាត្រា ៦៦ ក៏បានរួមបញ្ចូលទាំងការហាមឃាត់ជាទូទៅលើសកម្មភាពទូរគមនាគមន៍ដែលគ្រាន់តែ "អាចបង្កការប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ និងនាំឲ្យអន្តរាយសន្តិសុខជាតិ" ដោយគ្មានតម្រូវការនៃផលប៉ះពាល់ជាក់ស្តែងនោះទេ។ សកម្មភាពដែលគ្មានលទ្ធផលអវិជ្ជមានជាក់ស្តែងមួយ អាចនឹងត្រូវបានគេចាត់ទុកថាបានរំលោភលើច្បាប់នេះ និងត្រូវទទួលរងការពិន័យ។
- ច្បាប់នេះបង្កើតបទល្មើសថ្មីមួយ ចំពោះ "ការបញ្ចេញមតិ" តាមទូរគមនាគមន៍ ដែលចម្លងតាមបទប្បញ្ញត្តិដែលមានស្រាប់នៅក្នុងក្រមព្រហ្មទណ្ឌ ប៉ុន្តែបន្ថែមការដាក់ពិន័យខ្ពស់ជាងក្រមព្រហ្មទណ្ឌ ជាពិសេសចំពោះបទល្មើសទាក់ទងទៅនឹងការគំរាមកំហែងដែលត្រូវបានធ្វើឡើងតាមរយៈមធ្យោបាយទូរគមនាគមន៍។ បទល្មើសទាំងនេះមិនបានបន្ថែមអ្វីថ្មីដល់សំណុំច្បាប់ព្រហ្មទណ្ឌទេ លើកលែងតែការបង្កើនការពិន័យហិរញ្ញវត្ថុដោយមិនត្រឹមត្រូវ និងការបន្ថែមផលអវិជ្ជមាននៃ ទំនាស់រវាងច្បាប់។[១០] បទប្បញ្ញត្តិទាំងនេះក៏មានលក្ខខណ្ឌមិនច្បាស់ដោយចែងថា

---

[៩] មាត្រា ៨១ នៃច្បាប់ស្តីពីទូរគមនាគមន៍

[១០] មាត្រា ៩៣ នៃច្បាប់ស្តីពីទូរគមនាគមន៍ គឺស្មើទៅនឹងក្រមព្រហ្មទណ្ឌ មាត្រា ២៣១ (ការគំរាមកំហែង); ២៣២ (ការគំរាមកំហែងជាមួយនឹងការជំរិតទារប្រាក់) ២៣៣ (ការគំរាមសម្លាប់); ២៣៤ (ការគំរាមសម្លាប់ជាមួយនឹងការជំរិតទារប្រាក់) ។ មាត្រា ៩៥ នៃ ច្បាប់ស្តីពីទូរគមនាគមន៍ គឺចម្លងចេញពីក្រមព្រហ្មទណ្ឌ មាត្រា ៤២៣ (ការគំរាមកំហែងបណ្តាលឲ្យខូចខាត) និង ៤២៤ (ការគំរាមកំហែងបណ្តាលឲ្យខូចខាត បន្តដោយការបញ្ជា); ទោះជាយ៉ាងណា មាត្រា ៩៤ និង ៩៦ នៃច្បាប់ទូរគមនាគមន៍ អនុម័តការដាក់ពិន័យចំពោះបទល្មើសបែប

ការគំរាមកំហែងមួយត្រូវតែ "ធ្វើឡើងច្រើនជាងម្តង" តាមរយៈមធ្យោបាយទូរគមនាគមន៍ ដើម្បីឲ្យអ្នកប្រព្រឹត្តអាចមានទំនួលខុសត្រូវព្រហ្មទណ្ឌ ដោយធ្វើឲ្យពលរដ្ឋយល់មិនច្បាស់ថាតើពេលណាអ្នកទាំងនោះរំលោភលើច្បាប់ និងអាចមានហានិភ័យនៃការជាប់ពន្ធនាគារ។[១១]

- មាត្រា ៩៩ ចែងនូវការជាប់ទោសពន្ធនាគារពីប្រាំមួយខែ ទៅពីរឆ្នាំ និងការពិន័យជាប្រាក់ធ្ងន់ធ្ងរសម្រាប់ "ការផលិត ការដំឡើង ឬការចែកចាយនូវកម្មវិធីសូហ្វវែរ ឬការលាក់ឧបករណ៍ថតសំឡេងសម្រាប់ថតកិច្ចសន្ទនាណាមួយ" ដោយគ្មានការអនុញ្ញាតពីអាជ្ញាធរ។បទបញ្ញត្តិមិនច្បាស់លាស់នេះអាចមានសក្តានុពលក្នុងការបង្កើតជាបទព្រហ្មទណ្ឌទៅលើការប្រើប្រាស់ទូទៅ ការចែករំលែក ឬការអភិវឌ្ឍនៃកម្មវិធីសូហ្វវែរដូចជាកម្មវិធីស្ទាតហ្វូន។ ទាំងនេះគឺជាការដាក់ទោសដែលមិនសមាមាត្រ ដោយរួមបញ្ចូលទាំងការប្រើប្រាស់ធម្មតានិងស្របច្បាប់នៃឧបករណ៍ទូរគមនាគមន៍ កម្មវិធីសូហ្វវែរ និងបណ្តាញ។ ជាថ្មីម្តងទៀត បទល្មើសនេះហាក់បីដូចជាបង្កើតឲ្យមានការទទួលខុសត្រូវដ៏តឹងរ៉ឹង។[១២]
- មាត្រា ១០៧ បង្កើតការទទួលខុសត្រូវរបស់អ្នកដឹកនាំស្ថាប័ន ជំនួសឲ្យសកម្មភាពវិជ្ជាជីវៈរបស់សមាជិកបុគ្គលិកម្នាក់ៗ។ បទបញ្ញត្តិនេះក៏បញ្ជាក់ផងដែរថាការទទួលខុសត្រូវព្រហ្មទណ្ឌរបស់បុគ្គល គឺមិនចេះរលត់ ហើយទាំងបុគ្គលិកម្នាក់និងមេដឹកនាំដែលមានការទទួលខុសត្រូវក្នុងការធ្វើសេចក្តីសម្រេចចុងក្រោយនៅក្នុងអង្គការមួយ អាចនឹងត្រូវបានជាប់ការទទួលខុសត្រូវបទល្មើសព្រហ្មទណ្ឌចំពោះការចោទប្រកាន់បទល្មើសទូរគមនាគមន៍តែមួយ។ លើសពីនេះទៀត ស្ថាប័ននោះអាចប្រឈមមុខនឹងផលវិបាក ប្រសិនបើបុគ្គលិកតំណាង ឬអ្នកដឹកនាំត្រូវបានរកឃើញថាមានការទទួលខុសត្រូវព្រហ្មទណ្ឌចំពោះបទល្មើស។ ចំនុចនេះមានការងាយស្រួលក្នុងការបង្កនូវការគម្រាមកំហែងធ្ងន់ធ្ងរដល់ការងារតស៊ូមតិរបស់បុគ្គលនិងក្រុមនិងសង្គមស៊ីវិលជាទូទៅ។ មាត្រានេះ ក៏អាចនឹងអនុញ្ញាតឲ្យមានការកំនត់គោលដៅទៅលើក្រុមមនុស្ស និងអង្គការ តាមរយៈសកម្មភាពរបស់បុគ្គលផងដែរ។ នៅក្នុងបរិបទនៃការបោះឆ្នោតនាពេលខាងមុខនេះ នេះគឺជាការព្រួយបារម្ភយ៉ាងខ្លាំង ឧទាហរណ៍មាត្រានេះអាចធ្វើឲ្យគណបក្សជំទាស់ត្រូវបានកំណត់ជាគោលដៅចំពោះការបញ្ចេញមតិនយោបាយរបស់សមាជិក បេក្ខជន និងសកម្មជនរបស់បក្ស។ មាត្រានេះ ក៏បង្កើតការព្រួយបារម្ភយ៉ាងខ្លាំងចំពោះការបញ្ចេញមតិ

---

នេះធ្ងន់ធ្ងរជាងភាគីក្រមព្រហ្មទណ្ឌ។ ច្បាប់ស្តីពីទូរគមនាគមន៍ក៏អនុញ្ញាតឲ្យមានការពិន័យបន្ថែម ក្រោមមាត្រា ១៦៨ នៃក្រមព្រហ្មទណ្ឌស្របទៅនឹងមាត្រាដែលបានកំណត់ក្រោមច្បាប់ទូរគមនាគមន៍។

[១១] ការគំរាមកំហែងត្រូវធ្វើឡើង "ម្តងហើយម្តងទៀត" ក្រោមមាត្រា ៩៣ និង៩៥។

[១២] មាត្រា ៩៩ ក៏ដូចជាមាត្រា ១០០នៃច្បាប់ស្តីពីទូរគមនាគមន៍

ដោយសេរីតាមរយៈប្រព័ន្ធផ្សព្វផ្សាយព័ត៌មានផងដែរ ប្រសិនបើអ្នកកាសែតនិងបុគ្គលិកជាន់ខ្ពស់អាចនឹងត្រូវបានផ្តន្ទាទោសចំពោះការបញ្ចេញមតិ។[១៣]

- មាត្រា ៦៥ (ខ) បានតាក់តែងសិទ្ធិទទួលបានឯកជនភាពសម្រាប់បុគ្គលក្នុងការប្រើសេវាទូរគមនាគមន៍។[១៤] ទោះជាយ៉ាងណា ការការពារឯកជនភាពនិងការឆ្លើយឆ្លងនេះ មិនមានតម្លៃជាធំដុំនៅក្នុងការអនុវត្តនោះទេ ដោយសារការដាក់បញ្ចូលនូវប្រការលើកលែងមួយ ដែលអនុញ្ញាតឲ្យធ្វើការបដិសេធសិទ្ធិនេះ ប្រសិនបើ "ត្រូវបានកំណត់ដោយច្បាប់ជាក់លាក់ផ្សេងទៀត"។ ប្រការដែលជាករណីលើកលែងនេះ គឺមិនស្របនឹងរដ្ឋធម្មនុញ្ញនោះទេ។ សិទ្ធិទទួលបានការសម្ងាត់នៃការឆ្លើយឆ្លងនេះ ត្រូវបានចែងនៅក្នុងរដ្ឋធម្មនុញ្ញ[១៥] ដែលជាប្រភពសំខាន់បំផុតនៃច្បាប់ជាតិ និងជាផ្នែកមួយដែលមិនអាចខ្វះបាននៅក្នុងច្បាប់ជាតិធម្មតា។[១៦] មាត្រាផ្សេងៗទៀតនៃច្បាប់ស្តីពីទូរគមនាគមន៍ ក៏ធ្វើឲ្យឱនថយយ៉ាងធ្ងន់ធ្ងរចំពោះការគាំពារដែលមិនរឹងមាំនេះ ហើយអំណាចដែលច្បាប់នេះផ្តល់ទៅឲ្យអាជ្ញាធររដ្ឋ ក៏ជាការរំលោភបំពានរដ្ឋធម្មនុញ្ញផងដែរ។ ទោះជាយ៉ាងណាមាត្រា ៦៥ (ឆ) ផ្តល់នូវសិទ្ធិសេរីភាពក្នុងការបង្កើតសមាគមតាមរយៈទូរគមនាគមន៍ ដោយធ្វើការផ្អែកជាក់លាក់ទៅនឹងរដ្ឋធម្មនុញ្ញ។[១៧] មិនមានការពន្យល់ពីភាពមិនស៊ីចង្វាក់គ្នាចំពោះការការពារសិទ្ធិ និងការការពារទាំងនេះទេ។
- មាត្រា ៦៥ (គ) បង្កើតជាសិទ្ធិសម្រាប់អ្នកប្រើប្រាស់សេវាទូរគមនាគមន៍ជាបុគ្គល ដើម្បីចូលរួមក្នុងការពិគ្រោះយោបល់លើគោលនយោបាយ និងបទប្បញ្ញត្តិសម្រាប់វិស័យទូរគមនាគមន៍។ ប៉ុន្តែច្បាប់នេះត្រូវបានអនុម័តដោយមានការជូនដំណឹងតិចតួច និងគ្មានការពិគ្រោះយោបល់ដ៏មានអត្ថន័យ កង្វះតម្លាភាព និងមិនបានរាប់បញ្ចូលនូវការបញ្ចេញមតិពីអ្នកប្រើប្រាស់សេវាកម្មនោះទេ។[១៨]

---

[១៣] មាត្រា ១០៧ នៃច្បាប់ស្តីពីទូរគមនាគមន៍

[១៤] មាត្រា ៦៥(ខ) នៃច្បាប់ស្តីពីទូរគមនាគមន៍

[១៥] មាត្រា ៤០ នៃរដ្ឋធម្មនុញ្ញកម្ពុជា

[១៦] មាត្រា ១៥០ នៃរដ្ឋធម្មនុញ្ញកម្ពុជា

[១៧] មាត្រា ៦៥ (ឆ) នៃច្បាប់ទូរគមនាគមន៍; សេរីភាពនៃសមាគម និងការជួបប្រជុំអហិង្សា ត្រូវបានការពារក្រោមមាត្រា ៤១ និង ៤២ នៃរដ្ឋធម្មនុញ្ញកម្ពុជា ខណៈដែលមាត្រា ៣១ ក៏ទទួលស្គាល់ជាថ្នាក់ជាតិ និងគោរពបទដ្ឋានអន្តរជាតិ ដែលរួមមាន មាត្រា ២២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ

[១៨] មាត្រា ៦៥(គ) នៃច្បាប់ស្តីពីទូរគមនាគមន៍

## ការបំផ្លាញវត្ថុតាង

ច្បាប់ស្តីពីទូរគមនាគមន៍ បានបញ្ចូលនូវអំណាចក្នុងការបំផ្លាញភស្តុតាងដែលអាចរារាំងការជំនុំជម្រះក្តីប្រកបដោយយុត្តិធម៌មួយលើបុគ្គលណាម្នាក់ដែលត្រូវបានតុលាការចោទប្រកាន់ក្រោមច្បាប់នេះ។ នីតិវិធីនេះ គឺរំលោភបំពានទៅលើសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ និងត្រឹមតែជាការគោរពក្នុងទ្រឹស្តីទៅលើបន្ទុកនៃភស្តុតាងនិងនីតិរដ្ឋនៅក្នុងប្រព័ន្ធយុត្តិធម៌ផ្នែកព្រហ្មទណ្ឌនៅកម្ពុជាប៉ុណ្ណោះ ។ ការបំផ្លាញភស្តុតាង អាចក្លាយជាបទល្មើសព្រហ្មទណ្ឌដែលត្រូវបានអនុញ្ញាតដោយអាជ្ញាធររដ្ឋ និងអាចរារាំងបុគ្គលណាមួយដែលត្រូវបានតុលាការចោទប្រកាន់តាមច្បាប់នេះពីការធ្វើការការពារខ្លួនពេញលេញមួយ។

- មាត្រា ៧៦ បង្កើតឲ្យមាននូវនីតិវិធីមួយដែលមន្ត្រីអធិការកិច្ចទូរគមនាគមន៍អាចស្នើសុំទៅព្រះរាជអាជ្ញានូវសិទ្ធិបំផ្លាញវត្ថុតាង "ដោយអនុលោមតាមនីតិវិធីជាធរមាន" ប្រសិនបើវត្ថុតាងនោះត្រូវបានគេអះអាងថាជា "ផលិតផលហាមឃាត់ ឬមានគ្រោះថ្នាក់" ។[១៩] ឃ្លានេះ មិនមានភាពច្បាស់លាស់នូវអ្វីដែលជានីតិវិធីជាធរមាន (មាត្រាជាច្រើននៃក្រមនីតិវិធីព្រហ្មទណ្ឌដែលមានស្រាប់ និងមានកម្រិត បានហាមឃាត់ការបំផ្លាញភស្តុតាង ដោយអនុញ្ញាតត្រឹមតែការបោះចោលនូវឧបករណ៍នានាដែលខុសច្បាប់ ឬមានគ្រោះថ្នាក់ប៉ុណ្ណោះនៅក្នុងករណីដែលឧបករណ៍ទាំងនោះមិនត្រូវការជាភស្តុតាង ហើយមាត្រាទាំងនេះ មិនត្រូវបានយកទៅប្រើប្រាស់នៅក្នុងច្បាប់ស្តីពីទូរគមនាគមន៍នោះទេ)។ ការការពារជាច្រើនពាក់ព័ន្ធនឹងការដាក់បង្ហាញដែលពាក់ព័ន្ធនានា មិនត្រូវបានគេចែងនៅក្នុងច្បាប់ស្តីពីទូរគមនាគមន៍ឡើយ។ ក្រមនីតិវិធីព្រហ្មទណ្ឌ មិនបានចែងអំពីតួនាទីរបស់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការមានសិទ្ធិស្នើសុំព្រះរាជអាជ្ញាឲ្យធ្វើការបំផ្លាញភស្តុតាង និងរារាំងព្រះរាជអាជ្ញាពីការបោះចោលឧបករណ៍នានានៅក្នុងអំឡុងពេលនៃការស៊ើបអង្កេត ឬក្នុងសវនាការនោះទេ។ ផ្ទុយទៅវិញ ច្បាប់ស្តីពីទូរគមនាគមន៍ បានចែងពីសិទ្ធិក្នុងការធ្វើសកម្មភាពទាំងនេះទៅវិញ។ ការស្នើសុំទៅព្រះរាជអាជ្ញានៅតាមរបៀបនេះ គឺផ្ទុយនឹងមាត្រានានានៃក្រមនីតិវិធីព្រហ្មទណ្ឌ និងបង្ហាញថាភស្តុតាងដែលពាក់ព័ន្ធនានាអាចត្រូវបានបំផ្លាញចោលនៅដំណាក់កាលមុនពេលជំនុំជម្រះក្តី។ លើសពីនេះ និយមន័យនៃផលិតផលហាមឃាត់និងគ្រោះថ្នាក់នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ គឺមានដែនកំនត់ ដែលចំនុចនេះមិនត្រូវបានចែងនៅក្នុងច្បាប់ស្តីពីទូរគមនាគមន៍ឡើយ។ មិនមានការការពារនានានៅក្នុងច្បាប់ស្តីពីទូរគមនាគមន៍ឡើយ ដោយទុកឲ្យមាត្រានេះមានអត្ថន័យទូលាយដើម្បីរំលោភបំពាន។[២០]

---

[១៩] មាត្រា ៧៦ នៃច្បាប់ស្តីពីទូរគមនាគមន៍

[២០] មាត្រា ១១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ អនុញ្ញាតឲ្យព្រះរាជអាជ្ញាបោះចោលវត្ថុដែលមានគ្រោះថ្នាក់ ឬហាមឃាត់ នៅក្នុងករណីតែវត្ថុនោះមិនតម្រូវឲ្យក្លាយជាភស្តុតាង។ និយមន័យនៃពាក្យ "គ្រោះថ្នាក់" នៅក្នុងមាត្រានេះបានផ្តោតយ៉ាងពិតប្រាកដទៅលើអាវុធ ឬមនុស្សឬវត្ថុដែលមានសមត្ថភាពផ្ទុកនូវវិសេវផ្ទុះ។ មាត្រានេះ ក៏បានរារាំងការបោះចោលវត្ថុនានាដោយព្រះរាជអាជ្ញាអំឡុងពេលស៊ើបអង្កេត ឬនិតិវិធីនានាមុនការជំនុំជម្រះ ហើយផ្តល់នូវការប្តឹងទាស់ទៅនឹងសេចក្តីសម្រេចក្នុងការបោះចោលវត្ថុទាំងនោះ។ មាត្រា ១៦១ អនុញ្ញាតឲ្យតែ

- ដូចដែលបានកត់សម្គាល់ អំណាចទាំងនេះ អាចត្រូវបានគេប្រើប្រាស់ដើម្បីរារាំងការការពារពេញលេញមួយ ដោយការបំផ្លាញភស្តុតាងដែលអាចធ្វើឲ្យជនជាប់ចោទរួចទោស។ លើសពីនេះ ការផ្តល់អំណាចដល់ព្រះរាជអាជ្ញាក្នុងការបំផ្លាញភស្តុតាងដែលមន្ត្រីទាំងនោះមានកាតព្វកិច្ចតាមច្បាប់ក្នុងការដាក់បង្ហាញដើម្បីបំពេញកាតព្វកិច្ចស្តីពីបន្ទុកនៃភស្តុតាង (ដែលកាតព្វកិច្ចនេះស្របតាមគោលការណ៍នៃការសន្មតជាមុនថាគ្មានទោសរបស់ជនជាប់ចោទ) បង្ហាញពីកង្វះការប្តេជ្ញាចិត្តរបស់អាជ្ញាធរក្នុងការអនុវត្តតាមគោលការណ៍នីតិរដ្ឋ និងប្រព័ន្ធយុត្តិធម៌ដ៏ត្រឹមត្រូវមួយ។ មាត្រានេះ ត្រឹមតែបង្កើនលទ្ធភាពរបស់តុលាការក្នុងការត្រូវបានគេយកទៅប្រើប្រាស់ជាឧបករណ៍នយោបាយមួយដើម្បីគាបសង្កត់លើសេរីភាពក្នុងការបញ្ចេញមតិ ការជួបជុំ និងភាពសកម្មនិយមក្នុងលទ្ធិប្រជាធិបតេយ្យប៉ុណ្ណោះ។ យោងតាមក្រមព្រហ្មទណ្ឌ ការបំផ្លាញភស្តុតាង គឺជាបទល្មើសមួយ។[21] ដោយមិនមានការការពារនានា មាត្រានេះត្រឹមតែជានិទណ្ឌភាពសម្រាប់បទល្មើសព្រហ្មទណ្ឌមួយដែលអនុញ្ញាតដោយអាជ្ញាធររដ្ឋក្នុងការប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ប្រព័ន្ធយុត្តិធម៌ផ្នែកព្រហ្មទណ្ឌប៉ុណ្ណោះ។
- ច្បាប់នេះ ក៏អនុញ្ញាតឲ្យអាជ្ញាធរផ្ទេរបន្ទុកនៃការចំណាយនៃការបំផ្លាញភស្តុតាងទៅឲ្យជនជាប់ចោទផងដែរ។ លើសពីការរំលោភបំពានលើសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ ការបំផ្លាញភស្តុតាងដែលជារបស់បុគ្គលម្នាក់ គឺជាការរំលោភលើសិទ្ធិលើទ្រព្យសម្បត្តិដែលមិនអាចប្រកែកបាន ជាពិសេសនៅពេលដែលភាគីជនជាប់ចោទក្រោយមកត្រូវបានរួចពីការចោទប្រកាន់ ហើយឧបករណ៍ទាំងនោះមិនអាចត្រូវបានគេចាត់ទុកថាជាវត្ថុមានគ្រោះថ្នាក់ ឬខុសច្បាប់។

## ការត្រួតពិនិត្យ និងការពង្រឹងការប្រតិបត្តិទូរគមនាគមន៍

ច្បាប់ស្តីពីទូរគមនាគមន៍ បានចែងនូវមាត្រាជាច្រើនអំពីការត្រួតពិនិត្យ និងពង្រឹងការប្រតិបត្តិទូរគមនាគមន៍ ដែលលើសពីសេចក្តីព្រាងច្បាប់កាលពីពេលមុន។[២២]

- ជំពូកទី៣ បង្កើតអង្គភាពថ្មីមួយគឺ "មន្ត្រីអធិការកិច្ចទូរគមនាគមន៍" ដែលជាកងត្រួតពិនិត្យផ្នែកទូរគមនាគមន៍មានតួនាទី "ត្រួតពិនិត្យ សិក្សា តាមដាន និងពង្រឹងការអនុវត្តច្បាប់នេះ"។ ក្រៅពីតួនាទីស្របច្បាប់ក្នុងការអធិការកិច្ចលើហេដ្ឋារចនាសម្ព័ន្ធ និងបទបញ្ញានៃវិស័យទូរគមនាគមន៍ (ដោយសារមានបទល្មើសព្រហ្មទណ្ឌជាច្រើន) មន្ត្រីអធិការកិច្ចទូរគមនាគមន៍មានតួនាទីចំបងក្នុងការ "ការពារ និងបង្ក្រាបរាល់បទល្មើសនានាក្នុងវិស័យទូរគមនាគមន៍"។

---

ចៅក្រមស៊ើបសួរប៉ុណ្ណោះមានសិទ្ធិបោះចោលវត្ថុនៅដំណាក់កាលមុនសវនាការ ហើយនៅក្នុងតែករណីដែលវត្ថុទាំងនោះមានគ្រោះថ្នាក់ ឬហាមឃាត់ប៉ុណ្ណោះ (ការបោះចោល គឺត្រូវបានអនុញ្ញាតតែក្នុងករណីមិនមានផលប៉ះពាល់)។ មាត្រា ៣៥៤ ផ្តល់អំណាចក្នុងការបោះចោលវត្ថុមានគ្រោះថ្នាក់ ឬវត្ថុហាមឃាត់ដែលអាចជាភស្តុតាងដល់តុលាការ នៅពេលធ្វើសេចក្តីសម្រេចបញ្ចប់នៅក្នុងសវនាការ។

[២១] មាត្រា ៥៣៣ និង៥៣៩ នៃក្រមព្រហ្មទណ្ឌ

[២២] មាត្រា ៧០ (គ) នៃច្បាប់ស្តីពីទូរគមនាគមន៍

ក្នុងចំនុចនេះ អនុញ្ញាតឲ្យមានការត្រួតពិនិត្យ និងពិន័យពាក់ព័ន្ធទៅនឹងអត្ថបទលើប្រព័ន្ធអ៊ិនធើណេត និងការស៊ើបអង្កេតលើគ្រប់ទំនាក់ទំនងរវាងបុគ្គលនិងបុគ្គល។ លើសពីនេះ មន្ត្រីអធិការកិច្ចទូរគមនាគមន៍ មានអំណាចក្នុងការអនុវត្តភារកិច្ចផ្សេងទៀតដែលត្រូវបានបញ្ជាដោយរដ្ឋមន្ត្រីក្រសួងប្រៃណីយ៍ និងទូរគមនាគមន៍។[២៣]

- ភ្នាក់ងារនេះ មានអំណាចជាមន្ត្រីនគរបាលយុត្តិធម៌ពេញលេញស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌ។[២៤] ជាផ្នែកមួយនៃអំណាចស៊ើបអង្កេត មន្ត្រីអធិការកិច្ចទូរគមនាគមន៍ មានសិទ្ធិរឹបអូស និងថតចម្លងទិន្នន័យ ហើយ "ត្រួតពិនិត្យ" លើសម្ភារៈបរិក្ខារ។[២៥] នៅក្នុងករណីដែលមានការព្រួយបារម្ភកាន់តែខ្លាំង មន្ត្រីអធិការកិច្ចទូរគមនាគមន៍ អាចសុំជំនួយពីកងយុទ្ធពលខេមរភូមិន្ទ "ក្នុងការចូលរួមបង្ក្រាបបទល្មើសដូចដែលបានចែងនៅក្នុងច្បាប់នេះ" រួមទាំងការពង្រឹងការរឹតត្បិតមិនត្រឹមត្រូវនានាលើសេរីភាពជាមូលដ្ឋានរបស់បុគ្គលនៅក្នុងច្បាប់ស្តីពីទូរគមនាគមន៍ផងដែរ។[២៦] តួនាទីពិសេសសម្រាប់មន្ត្រីអធិការកិច្ចទូរគមនាគមន៍ និងកងកម្លាំងប្រដាប់អាវុធក្នុងការ "បង្ក្រាប" ទៅលើសេរីភាពនៅក្នុងការបញ្ចេញមតិ និងជួបជុំរបស់បុគ្គល គឺមិនមានភាពសមាមាត្រ និងមិនចាំបាច់នោះទេ។ ប៉ុន្តែតួនាទីនេះ ត្រឹមតែជាការអនុញ្ញាតរបស់ច្បាប់ដល់អាជ្ញាធររដ្ឋក្នុងការបំភិតបំភ័យ និងធ្វើការបំផ្លាញសកម្មភាពណាមួយតាមប្រព័ន្ធទូរគមនាគមន៍ដែលអាជ្ញាធរទាំងនោះគិតថាជាសកម្មភាពជំទាស់។ មន្ត្រីអធិការកិច្ចទូរគមនាគមន៍ ក៏មានអំណាចក្នុងការព្យួរជាបណ្តោះអាសន្ននូវសេវាទូរគមនាគមន៍របស់ប្រតិបត្តិករ/ក្រុមហ៊ុន និងព្យួរឬបណ្តេញបុគ្គលិករបស់ប្រតិបត្តិករ/ក្រុមហ៊ុននោះ។[២៧] យើងអាចដឹងមុនថា អំណាចទាំងនេះ អាចត្រូវបានគេប្រើប្រាស់មិនត្រឹមត្រូវដើម្បីរំលោភបំពានលើការបញ្ចេញមតិ និងការជួបជុំបែបប្រជាធិបតេយ្យ មុនពេលមានការបោះឆ្នោតដែលនឹងខិតជិតមកដល់។

## ការគ្រប់គ្រងដោយអាជ្ញាធររដ្ឋហួសហេតុ

ជំពូកទី២ និងមាត្រា ២៤ នៃច្បាប់នេះ ដាក់ឧស្សាហកម្មទូរគមនាគមន៍ ហេដ្ឋារចនាសម្ព័ន្ធ និងសកម្មភាពដែលពាក់ព័ន្ធនឹងវិស័យទូរគមនាគមន៍ទាំងអស់ ឲ្យនៅក្រោមអំណាចរបស់ក្រសួងប្រៃណីយ៍ និងទូរគមនាគមន៍។[២៨]

---

[២៣] មាត្រា ៧០ (ខ) និង (ង) នៃច្បាប់ស្តីពីទូរគមនាគមន៍

[២៤] មាត្រា ៧១ នៃច្បាប់ស្តីពីទូរគមនាគមន៍ និងក្រមនីតិវិធីព្រហ្មទណ្ឌ

[២៥] មាត្រា ៧០ (ក) (គ) និង (ឃ) នៃច្បាប់ស្តីពីទូរគមនាគមន៍

[២៦] មាត្រា ៧២ នៃច្បាប់ស្តីពីទូរគមនាគមន៍

[២៧] មាត្រា ៧៤ និង៧៨ (២) នៃច្បាប់ស្តីពីទូរគមនាគមន៍

[២៨] ជំពូកទី២ និងមាត្រា ២៤ នៃច្បាប់ស្តីពីទូរគមនាគមន៍

- មាត្រា ៨ នៃច្បាប់នេះបានលើក និយ័តករទូរគមនាគមន៍កម្ពុជា (ន.ទ.ក) ដែលមានស្រាប់ទៅជាគោល នៅពេលដែលមាត្រា ៩ បានចែងថាប្រធាន ន.ទ.ក មានឋានៈស្មើនឹងរដ្ឋលេខាធិការក្រសួងប្រៃណីយ៍ និងទូរគមនាគមន៍។[២៩]
- ន.ទ.ក ទទួលខុសត្រូវក្នុងការអនុវត្តជាក់ស្តែងលើច្បាប់ស្តីពីទូរគមនាគមន៍ និងទទួលបានអំណាចលើសលុបតាមមាត្រា ១២ រួមទាំងអំណាចក្នុងការស៊ើបអង្កេត និងចាត់វិធានការលើប្រតិបត្តិករទូរគមនាគមន៍នានាដែលល្មើសនឹងច្បាប់នេះ។[៣០]
- មាត្រា ៧ នៃច្បាប់ស្តីពីទូរគមនាគមន៍ បានចែងថា នៅក្នុងករណី "ប្រធានសក្តិ" ក្រសួងប្រៃណីយ៍ និងទូរគមនាគមន៍ ឬក្រសួង ស្ថាប័នមានសមត្ថកិច្ច អាចបញ្ជាទៅប្រតិបត្តិករទូរគមនាគមន៍ឯកជនឲ្យ "ចាត់វិធានការចាំបាច់"។[៣១] មាត្រានេះ ត្រូវបានចែងដោយមិនត្រឹមត្រូវ ហើយមិនបានបញ្ជាក់ពីស្ថានភាពប្រធានសក្តិបែបណាដែលបណ្តាលឲ្យអាជ្ញាធររដ្ឋមានអំណាចសម្រេចបញ្ជាដោយផ្ទាល់ទៅលើការប្រតិបត្តិរបស់ក្រុមហ៊ុនឯកជននានា ឬអ្វីដែលជា "វិធានការចាំបាច់"។ ចំនុចនេះធ្វើឲ្យមាត្រានេះ ងាយត្រូវបានគេយកទៅប្រើប្រាស់មិនត្រឹមត្រូវ។ យើងអាចដឹងមុនបានថា មាត្រានេះ អាចត្រូវបានគេរំលោភបំពានដើម្បីបិទបណ្តាញសង្គម និងសេវាកម្មផ្សេងៗទៀតដែលប្រើប្រាស់តាមប្រព័ន្ធអ៊ិនធើណេតជាបណ្តោះអាសន្ន ដូចជាកម្មវិធីផ្ញើរសារនានា។ ការបិទនេះ ជាមធ្យោបាយដើម្បីរារាំងការប្រមូលផ្តុំគ្នាដោយប្រើបណ្តាញសង្គម ដូចដែលបានកើតឡើងនៅក្នុងរបបដែលគាបសង្កត់ដទៃទៀត។[៣២] ក៏ធ្លាប់មានកើតឡើងពីមុនមកផងដែរចំពោះការបិទនេះនៅក្នុងប្រទេសកម្ពុជា គឺនៅឆ្នាំ ២០០៧ មុនពេលមានការបោះឆ្នោតឃុំសង្កាត់លើកទីពីរទូទាំងប្រទេស ដោយអាជ្ញាធររដ្ឋបានព្យួរប្រព័ន្ធផ្ញើរសារតាមទូរស័ព្ទដៃអស់រយៈពេលពេញមួយថ្ងៃនៅក្នុងប្រទេស ដើម្បីបង្អាក់ដល់ការងារអ្នកឃ្លាំមើលការបោះឆ្នោត។[៣៣]
- របបអាជ្ញាប័ណ្ណដែលមានស្រាប់ដែលក្រោមការគ្រប់គ្រងរបស់អាជ្ញាធររដ្ឋ កាន់តែមានភាពតឹងរឹង ហើយច្បាប់ស្តីពីទូរគមនាគមន៍ មិនបានផ្តល់សិទ្ធិក្នុងការប្តឹងទាស់ ឬធ្វើឲ្យមានការការពារកាន់តែប្រសើរពាក់ព័ន្ធនឹងសេចក្តីសម្រេចផ្តល់អាជ្ញាប័ណ្ណដោយមិនត្រឹមត្រូវនោះទេ។
សកម្មភាពដែលគ្មានអាជ្ញាប័ណ្ណ នឹងត្រូវទទួលទណ្ឌកម្មជាប់ឃុំឃាំង និងទោសពិន័យជាប្រាក់យ៉ាងច្រើន។[៣៤] នៅខណៈដែលរបបនៃការផ្តល់អាជ្ញាប័ណ្ណ មិនមែនជាការអនុវត្តតាមច្បាប់ពិសេសនោះទេ ប៉ុន្តែនៅក្នុងបរិបទនៃប្រទេសកម្ពុជា អាជ្ញាធររដ្ឋអាចយកមាត្រាទាំងនេះទៅ

---

[២៩] មាត្រា ៨ និង៩ នៃច្បាប់ស្តីពីទូរគមនាគមន៍

[៣០] មាត្រា ១២ ជាពិសេសចំនុច (ដ) នៃច្បាប់ស្តីពីទូរគមនាគមន៍

[៣១] មាត្រា ៧ នៃច្បាប់ស្តីពីទូរគមនាគមន៍

[៣២] http://www.theguardian.com/world/2011/jan/26/egypt-blocks-social-media-websites; http://www.ibtimes.com/thailand-internet-censorship-government-orders-service-providers-block-criticism-take-1770220

[៣៣] http://www.washingtonpost.com/wp-dyn/content/article/2007/03/30/AR2007033000944.html

[៣៤] មាត្រា ១៤ ១៥ ១៦ ១៧ ១៨ ២០ ៧៨ ៨៩ និង៩១ នៃច្បាប់ស្តីពីទូរគមនាគមន៍

ប្រើប្រាស់ដើម្បីរក្សាការគ្រប់គ្រងលើប្រព័ន្ធផ្សព្វផ្សាយប្រពៃណី និងអ្នកផ្តល់សេវាអ៊ិនធើណេត។ មាត្រា ១១០ តម្រូវឲ្យប្រតិបត្តិករទូរគមនាគមន៍ត្រូវដាក់ពាក្យសុំអាជ្ញាប័ណ្ណជាថ្មីក្នុងរយៈពេល ១ឆ្នាំ បន្ទាប់ពីច្បាប់ស្តីពីទូរគមនាគមន៍ចូលជាធរមាន។[៣៥] នេះមានន័យថាអាជ្ញាធររដ្ឋនឹងសម្រេចចិត្តថាតើគួរអនុញ្ញាតឲ្យបន្តប្រតិបត្តិការនៃស្ថានីយ៍ទូរទស្សន៍ វិទ្យុ និងអ្នកផ្តល់នូវសេវាអ៊ិនធើណេតនានាដែរឬទេនៅពេលដែលការបោះឆ្នោតថ្នាក់ឃុំ-សង្កាត់ខិតជិតមកដល់នៅឆ្នាំ ២០១៧។

- ទោះបីជា ន.ទ.ក មានកាតព្វកិច្ចត្រូវតែផ្តល់ការជូនដំណឹងជាលាយល័ក្ខអក្សរអំពីការសម្រេចចិត្តរបស់ខ្លួនក៏ដោយ ក៏នៅតែមានកង្វះខាតតម្លាភាពពាក់ព័ន្ធនឹងហេដ្ឋារចនាសម្ព័ន្ធទូរគមនាគមន៍ (ឧទាហរណ៍ ល្បឿនប៊េនវីដ (bandwidth)) ដែលនេះធ្វើឲ្យមិនមានលទ្ធភាពបញ្ជាក់ថាតើមូលហេតុរបស់ ន.ទ.ក ក្នុងការបដិសេធផ្តល់អាជ្ញាប័ណ្ណ គឺស្របច្បាប់ឬទេ។[៣៦]
- យោងតាមមាត្រា ៨៩ សកម្មភាពណាមួយនៃការប្រតិបត្តិការទូរគមនាគមន៍ជាមូលដ្ឋាន[៣៧] ដែលមិនមានអាជ្ញាប័ណ្ណ អាចនឹងត្រូវបានទទួលទោសជាប់ឃុំឃាំង និងពិន័យជាប្រាក់រហូតដល់ ៥ លានរៀល។[៣៨] ឧបសម្ព័ន្ធនៃច្បាប់ស្តីពីទូរគមនាគមន៍នេះ បង្កើតនូវនិយមន័យយ៉ាងទូលំទូលាយនៃពាក្យ "គ្រឿងសម្ភារបរិក្ខារទូរគមនាគមន៍" ដោយបានរួមបញ្ចូលនូវគ្រប់សម្ភារអេឡិចត្រូនិចទាំងអស់ដែលត្រូវបានប្រើប្រាស់ក្នុងប្រព័ន្ធទូរគមនាគមន៍[៣៩]។ នេះមានន័យថាឧបករណ៍ទំហំតូចដែលមិនមានអាជ្ញាប័ណ្ណ ឬការជួសជុលឧបករណ៍នានាដូចជាទូរស័ព្ទចល័ត ឬកុំព្យូទ័រ ក៏អាចត្រូវបានទទួលទោសឃុំខ្លួនផងដែរ។ យោងតាមមាត្រា ៩១ ការសាងសង់ ឬការប្រតិបត្តិហេដ្ឋារចនាសម្ព័ន្ធ និងសេវាទូរគមនាគមន៍នានាដោយមិនមានអាជ្ញាប័ណ្ណ នឹងត្រូវផ្តន្ទាទោសជាប់ពន្ធនាគាររហូតដល់ ៣ឆ្នាំ។[៤០] ដូចនេះ ច្បាប់ស្តីពីទូរគមនាគមន៍ផ្តល់អំណាចដល់អាជ្ញាធររដ្ឋក្នុងការរឹតត្បិត និងការគ្រប់គ្រងការផ្តល់អាជ្ញាប័ណ្ណដោយមិនត្រឹមត្រូវទៅលើការប្រើប្រាស់ប្រព័ន្ធទូរគមនាគមន៍រាប់តាំងពីថ្នាក់បុគ្គលម្នាក់ៗរហូតដល់អ្នកផ្តល់សេវាទូរគមនាគមន៍ធំៗ។

## ការជ្រៀតជ្រែករបស់អាជ្ញាធររដ្ឋ និងសិទ្ធិលើទ្រព្យសម្បត្តិឯកជន

ច្បាប់ស្តីពីទូរគមនាគមន៍ ផ្តល់អំណាចយ៉ាងច្រើនលើសលុបឲ្យដល់ស្ថាប័នអាជ្ញាធររដ្ឋក្នុងការជ្រៀតជ្រែកប្រតិបត្តិការផ្ទៃក្នុងរបស់ប្រតិបត្តិករទូរគមនាគមន៍ឯកជន។ នេះ អាចនឹងមានគ្រោះថ្នាក់

---

[៣៥] មាត្រា ១១០ នៃច្បាប់ស្តីពីទូរគមនាគមន៍

[៣៦] មាត្រា ២០ (គ) នៃច្បាប់ស្តីពីទូរគមនាគមន៍ តម្រូវឲ្យ ន.ទ.ក ផ្តល់នូវការសម្រេចចិត្តដែលមានមូលហេតុ ប៉ុន្តែមិនមានយន្តការសំខាន់សម្រាប់ការប្តឹងទាស់លើការបដិសេធក្នុងការផ្តល់អាជ្ញាប័ណ្ណនោះទេ។

[៣៧] មាត្រា ១៥ នៃច្បាប់ស្តីពីទូរគមនាគមន៍

[៣៨] មាត្រា ៨៩ នៃច្បាប់ស្តីពីទូរគមនាគមន៍

[៣៩] ឧបសម្ព័ន្ធនៃច្បាប់ស្តីពីទូរគមនាគមន៍

[៤០] មាត្រា ១៧ និង៩១ នៃច្បាប់ស្តីពីទូរគមនាគមន៍

ប្រសិនបើមាត្រាដែលនឹងត្រូវបានពិភាក្សាខាងក្រោម ត្រូវបានគេយកទៅប្រើប្រាស់មិនត្រឹមត្រូវដើម្បីប្រែក្លាយក្រុមហ៊ុនឯកជនដែលឯករាជ្យទៅជាក្រុមហ៊ុន និងឧបករណ៍របស់អាជ្ញាធររដ្ឋ ក្នុងការធ្វើសកម្មភាពគាបសង្កត់។

- ន.ទ.ក មានសិទ្ធិក្នុងការព្យួរ ឬបញ្ឈប់ការងាររបស់បុគ្គលិកជាន់ខ្ពស់នៃប្រតិបត្តិករទូរគមនាគមន៍នានា ប្រសិនបើប្រតិបត្តិករទូរគមនាគមន៍ល្មើសនឹងច្បាប់ស្តីពីទូរគមនាគមន៍។[៤១] មិនមានភាពច្បាស់លាស់ ថាតើតម្រូវឲ្យមានសេចក្តីសម្រេចចុងក្រោយរបស់ចៅក្រមដើម្បីប្រើប្រាស់នៃអំណាចនេះ ឬក៏ន.ទ.ក អាចប្រកាសអំពីការរំលោភនេះ ដើម្បីធ្វើឲ្យការជ្រៀតជ្រែករបស់អង្គភាពនេះទៅក្នុងប្រតិបត្តិការផ្ទៃក្នុងរបស់ក្រុមហ៊ុនទៅជាស្របច្បាប់នោះទេ។
- ន.ទ.ក ក៏មានសិទ្ធិអំណាចក្នុងការជ្រើសរើសបុគ្គលិកដើម្បីជំនួសបុគ្គលិករបស់ក្រុមហ៊ុនឯកជនដែលត្រូវបានទទួលទណ្ឌកម្មដោយការព្យួរ ឬបញ្ឈប់ពីការងារ ដោយយោងតាមច្បាប់ស្តីពីទូរគមនាគមន៍ ដើម្បីសម្របសម្រួល និង "ពិនិត្យ" លើសកម្មភាពនានារបស់ក្រុមហ៊ុនដែលបានល្មើសនឹងច្បាប់នេះ។[៤២] លើសពីនេះ ន.ទ.ក អាចបញ្ជាឲ្យមានការរឹតបន្តឹងលើសកម្មភាពនានារបស់ប្រតិបត្តិករទូរគមនាគមន៍ ដោយមិនគិតពីការប្រតិបត្តិតាមលក្ខខណ្ឌនៅក្នុងការផ្តល់អាជ្ញាប័ណ្ណនោះទេ។[៤៣] កង្វះខាតភាពច្បាស់លាស់ពីឋានៈ ឬភាពអចិន្ត្រៃយ៍នៃបុគ្គលិកដែលត្រូវបានជ្រើសរើសដោយអាជ្ញាធររដ្ឋនៅក្នុងក្រុមហ៊ុនទូរគមនាគមន៍ ធ្វើឲ្យក្លាយជាការព្រួយបារម្ភអំពីអាយុកាល និងការគ្រប់គ្រងរបស់អាជ្ញាធររដ្ឋទៅលើក្រុមហ៊ុន និងទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនឯកជន។[៤៤]
- មាត្រា ៦៩ ចែងមិនស៊ីចង្វាក់គ្នា ដោយបានផ្តល់សិទ្ធិអំណាចដល់ ន.ទ.ក និងតុលាការ ក្នុងការបញ្ជាឲ្យផ្តល់សំណងនៅក្នុងជម្លោះរវាងប្រតិបត្តិករទូរគមនាគមន៍។[៤៥] អំណាចរបស់ ន.ទ.ក ក្នុងការបញ្ជាឲ្យផ្តល់សំណង គឺរំលោភលើអំណាចរបស់តុលាការ[៤៦] ហើយរំលោភលើគោលការណ៍នៃការបែងចែកអំណាចដាច់ពីគ្នាដែលត្រូវបានចែងក្នុងរដ្ឋធម្មនុញ្ញ។[៤៧]

---

[៤១] មាត្រា ៧៨ (២) (ក) នៃច្បាប់ស្តីពីទូរគមនាគមន៍

[៤២] មាត្រា ៧៨ (២) (ខ) នៃច្បាប់ស្តីពីទូរគមនាគមន៍

[៤៣] មាត្រា ៧៨ (២) (គ) នៃច្បាប់ស្តីពីទូរគមនាគមន៍

[៤៤] មាត្រា ៤៩ នៃរដ្ឋធម្មនុញ្ញកម្ពុជា មាត្រា ៧ និង៧៨ នៃច្បាប់ស្តីពីទូរគមនាគមន៍

[៤៥] មាត្រា ៦៩ នៃច្បាប់ស្តីពីទូរគមនាគមន៍

[៤៦] មាត្រា ៣៩ នៃរដ្ឋធម្មនុញ្ញកម្ពុជា

[៤៧] មាត្រា ៦៩ នៃច្បាប់ស្តីពីទូរគមនាគមន៍ គោលការណ៍បែងចែកអំណាចដាច់ពីគ្នា ត្រូវបានចែងនៅក្នុងមាត្រា ៥១ ១២៨ ១២៩ និង១៣០